ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធី**
**ចម្រើនព្រះជន្មគម្រប់ ៦២ យាងចូល ៦៣ ព្រះវស្សា**
**១៤.៥.១៩៥៣ - ១៤.៥.២០១៥**

**សូមក្រាបថ្វាយបង្គំ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃព្រះរាជពិធីចម្រើនព្រះជន្មគម្រប់ **៦២** យាងចូល **៦៣** ព្រះវស្សារបស់ព្រះអង្គ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ នេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំង នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត នូវកតញ្ញូកតវេទិតាធម៌ចំពោះ ព្រះមហាករុណាទិគុណរបស់ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ដែលព្រះអង្គបានបំពេញព្រះរាជបេសកកម្មក្នុងប្រទេស ក្រៅប្រទេស ដើម្បីកិត្តិស័ព្ទ កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា និងដើម្បីជាម្លប់របស់ប្រជារាស្ត្រកម្ពុជា ក្នុងការថែរក្សានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងអភិវឌ្ឍន៍ជាតិមាតុភូមិអង្គរជាទីស្នេហា ឆ្ពោះទៅរកវឌ្ឍនភាពរុងរឿង និងជាទីសង្ឃឹមដល់ប្រជាពលរដ្ឋខ្មែរគ្រប់ៗ រូបទាំងក្នុងបច្ចុប្បន្ននិងទៅអនាគត។

រៀងរាល់ពេលដែលប្រជាពលរដ្ឋ ជាកូនចៅរបស់ព្រះអង្គ ទទួលរងគ្រោះដោយគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយផ្សេងៗ ពិសេសប្រជាពលរដ្ឋដែលជួបប្រទះការលំបាក ទីទ័លក្រនៅតាមតំបន់ជនបទដាច់ស្រយាលនានាក្នុងទូទាំងប្រទេស ព្រះអង្គតែងតែយាងចុះសាកសួរសុខទុក្ខ និងចែកអំណោយជូនដល់ប្រជា-រាស្ត្រជាកូនចៅរបស់ព្រះអង្គជានិច្ច។

ក្នុងចុងឆ្នាំ២០១៤ កន្លងមក ដោយមានព្រះរាជអន្តរាគមន៍របស់ព្រះអង្គ គណបក្សធំៗ ទាំងពីរដែលមានអាសនៈក្នុងសភាបានឯកភាពគ្នាដោះស្រាយបញ្ហានយោបាយ ដែលកើតមានក្រោយការបោះឆ្នោត

ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ និងចូលរួមប្រជុំសភាពិភាក្សារកដំណោះស្រាយ ដើម្បីភាពសុខដុមរមនា រក្សាបានឧត្តមប្រយោជន៍ជូនប្រទេសជាតិ និងភាពរស់នៅសុខសាន្តជូនប្រជាពលរដ្ឋ ដោយប្រកាន់យក "**វប្បធម៌សន្ទនា**" ជាគ្រឹះ សម្រាប់ដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើងក្នុងសង្គម។

**ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់** !

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមប្តេជ្ញា ធ្វើពលីកម្មគ្រប់បែបយ៉ាង ដង្ហែតាមព្រះរាជតម្រិះដ៏ត្រឹមត្រូវរបស់ព្រះអង្គ ក្នុងគ្រប់បេសកកម្ម ដើម្បីបុព្វហេតុបម្រើឧត្តមប្រយោជន៍ **ជាតិ សាសនា ព្រះមហាក្សត្រ**។

ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃព្រះរាជពិធីចម្រើនព្រះជន្មនាពេលនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត បួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកមានទេវតារក្សាព្រះមហាស្វេតឆ័ត្រ **ទេវតារក្សាឆ្នាំថ្មី** ឆ្នាំ **មមែ** សប្តស័ក ព.ស ២៥៥៩ ព្រមទាំងព្រះរាជតេជបារមី នៃព្រះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានប្រសិទ្ធិពរជ័យ **សិរីមង្គល វិបុលសុខ មហាប្រសើរ** ថ្វាយព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីសក្ការៈ សូមព្រះអង្គទ្រង់ប្រកបដោយ ព្រះបរមសុខ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលខ្លាំងក្លាមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីទ្រង់គង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ព្រមទាំងប្រជាពលរដ្ឋខ្មែរជារៀងរហូតតទៅ។

សូម ព្រះករុណា ជាអម្ចាស់ជាទីសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់ អំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**